ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

36

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី
លេខ ៖ ១៨២
ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣
សាលដីកា
លេខ ៖ ៦៨ (ថ)
ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤

## នាមនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅសាលសវនាការជាសាធារណៈ

នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤

សមាសភាពក្រុមប្រឹក្សាជំនុំជំរះ

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោកស្រី ជាចៅក្រម

### ក្រឡាបញ្ជី

លោក [redacted]

### តំណាងមហាអយ្យការ

លោក [redacted] ជាព្រះរាជអាជ្ញា

-ដើមចោទឈ្មោះ [redacted] មនោរិទ្ធ "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៤៣ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

មានមេធាវីលោក [redacted] តំណាងដោយអាណត្តិ

-ចុងចំលើយឈ្មោះ [redacted] សេរីកញ្ញា "ជាចុងបណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។

មានមេធាវីលោក [redacted] តំណាងដោយអាណត្តិ



Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

<u>កម្មវត្ថុបណ្ដឹង</u> : ប្ដឹងសុំលែងលះ, សុំសិទ្ធិគ្រប់គ្រងកូនចំនួន២នាក់, បែងចែកទ្រព្យសម្បត្តិ និងបំណុលរួម។

## អំពីអង្គហេតុ និង ចំណុចទាមទារ :

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ</u>

តាមពាក្យបណ្ដឹង ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២ របស់ដើមចោទឈ្មោះ [redacted] មនោរិទ្ធ ថាៈ ខ្លួនសុំលែងលះពីប្រពន្ធឈ្មោះ [redacted] សេរីកញ្ញា ឱ្យបានដាច់ស្រឡះចាប់ពីថ្ងៃនេះតទៅ, សុំសិទ្ធិគ្រប់គ្រងកូនឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ១៤ឆ្នាំ និងឈ្មោះ [redacted] វិជ្ជោត ភេទប្រុស អាយុ១២ឆ្នាំ, សុំបែងចែកទ្រព្យរួមមាន ផ្ទះថ្មក្រោមឈើខាងលើទំហំ៧ម៉ែត្រx២៤ម៉ែត្រ ដែលសង់នៅលើដីលំនៅដ្ឋានទំហំ១០ម៉ែត្រx៣០ម៉ែត្រ ស្ថិតនៅភូមិពោធិសែនស្ពាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ រថយន្តម៉ាកកូរ៉ូឡា ពណ៌ក្រហមផលិតនៅឆ្នាំ២០០១ ស្លាកលេខភ្នំពេញ 2R-0087 តម្លៃ១០៥០០ដុល្លារអាមេរិក ដែលប្រពន្ធជាអ្នកគ្រប់គ្រងសព្វថ្ងៃ ផ្ទះសំណាក់យីហោឈានឡើង ទំហំ១១ម៉ែត្រx២៤ម៉ែត្រ និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីលំនៅដ្ឋានទំហំ២១ម៉ែត្រគុណ៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ។ ដីលំនៅដ្ឋានទំហំ២១ម៉ែត្រx៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងបំណុលរួចមានៈ ជំពាក់បងប្អូនចំនួន៤៨.៨៤២ដុល្លារអាមេរិក, បងឡាសំណាង់ចំនួន៤.០០០ដុល្លារអាមេរិក, បងសានចំនួន៩.៥០០ដុល្លារអាមេរិក, បងរុំចំនួន១.៨០០ដុល្លារអាមេរិក, ធនាគារអេស៊ីលីដាចំនួន១២.០០០ដុល្លារអាមេរិក, ជំពាក់ថ្លៃភ្លើងចំនួន៥០០ដុល្លារអាមេរិក, ជំពាក់បងហៃចំនួន៣០០ដុល្លារអាមេរិក, ជំពាក់ពូឡេឡាចំនួន៣០០ដុល្លារអាមេរិក និងឈ្មោះ ផល ចំនួន៣០០ដុល្លារអាមេរិក សរុបបំណុលរួមចំនួន៧៧.៥០០ដុល្លារអាមេរិក។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ១៥ "ក" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅៈ

១-ឱ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ និងចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា លែងលះពីគ្នាចាប់ពីពេលសាលក្រមចូលស្ថាពរតទៅ តាមបញ្ញត្តិមាត្រា៩៧៩ នៃក្រមរដ្ឋប្បវេណី។

២-ឱ្យចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ស្ថិតក្នុងភាពមេម៉ាយចំនួន១២០ថ្ងៃ គិតចាប់ពីពេលសាលក្រមចូលស្ថាពរតទៅ តាមបញ្ញត្តិមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី។

៣-ឱ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ១៤ឆ្នាំ និងឈ្មោះ [redacted] វិជ្ជោត ភេទប្រុស អាយុ១២ឆ្នាំ តាមការព្រមព្រៀងរបស់គូភាគី តាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី។

៣៦៥



Scanned with CamScanner

៤-ឱ្យចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ជាម្ដាយ ដែលពុំមានអំណាចមេបាលើកូន ឈ្មោះ [redacted] ហេងហេង ភេទស្រី អាយុ១៤ឆ្នាំ និងឈ្មោះ [redacted] វិជ្ជាត ភេទប្រុស អាយុ១២ឆ្នាំ មានសិទ្ធិចូលជួប និងប្រាស្រ័យទាក់ទងជាមួយកូន និងមានករណីកិច្ចទទួលបន្ទុកលើសោហ៊ុយ ដែលចាំបាច់ដើម្បីគ្រប់គ្រងថែរក្សាកូន តាមបញ្ញត្តិមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី។

៥-ឱ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ជាអ្នកមានសិទ្ធិគ្រប់គ្រងលើដីលំនៅដ្ឋានដែលមានទំហំ២១ម៉ែត្រx៦០ម៉ែត្រ ដែលស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ និងដីព្រមទាំងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់ខារ៉ាអូខេ ដែលសង់លើដីទំហំ២១ម៉ែត្រx៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកប្រគល់ឱ្យកូននៅពេលកូនទាំងពីរនាក់មានវ័យជានីតិជន តាមការព្រមព្រៀងរបស់គូភាគី។

៦-ឱ្យចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ជាអ្នកមានសិទ្ធិគ្រប់គ្រងដីលំនៅដ្ឋាន និងផ្ទះ ដែលដីនោះមានទំហំ១០ម៉ែត្រx៣០ម៉ែត្រ ស្ថិតនៅភូមិពោធិ៍សែនស្ពាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ ដើម្បីទុកប្រគល់ឱ្យកូននៅពេលកូនទាំងពីរនាក់មានវ័យជានីតិជនតាមការព្រមព្រៀងរបស់គូភាគី។

៧-ឱ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ជាអ្នករ៉ាប់រងសងបំណុលរួមទាំងអស់ លើកលែងតែបំណុលដែលជំពាក់ធនាគារអេស៊ីលីដា តាមកិច្ចសន្យា ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១២ ដែលខ្ចីចំនួន៦.០០០(ប្រាំមួយពាន់)ដុល្លារអាមេរិក នោះ ចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ជារ៉ាប់រងសងតាមការព្រមព្រៀងរបស់គូភាគី។

៨-ឱ្យដើមចោទឈ្មោះ [redacted] មនោរិទ្ធ ប្រគល់ប្រាក់ចំនួន២២.០០០(ពីរម៉ឺនពីរពាន់) ដុល្លារអាមេរិក ទៅចុងចម្លើយឈ្មោះ [redacted] សេរីកញ្ញា ដោយការប្រគល់មានពីរដំណាក់កាល គឺដំណាក់កាលទី១ ដើមចោទប្រគល់ប្រាក់ចំនួន១១.០០០(មួយម៉ឺនមួយពាន់) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយនៅសប្ដាហ៍ទី១ ខែមករា ឆ្នាំ២០១៣ និងដំណាក់កាលទី២ ដើមចោទប្រគល់ប្រាក់ចំនួន១១.០០០(មួយម៉ឺនមួយពាន់)ដុល្លារអាមេរិកទៀត ឱ្យទៅចុងចម្លើយនៅសប្ដាហ៍ទី៤ ខែកុម្ភៈ ឆ្នាំ២០១៣ តាមការព្រមព្រៀងរបស់គូភាគី។

៩-រឹបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទបានបង់រួចហើយ។

សាលក្រមនេះប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ ហើយ សាម៉ីខ្លួនមានសិទ្ធិប្ដឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ២៧ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ ជិន្ទ មនោរិទ្ធ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ១៥ "ក" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ធំ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៥ "ក្រ.IV.ត" ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ៖

១-ច្រានចោលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ របស់ឈ្មោះ [redacted] មនោរិទ្ធ លើកលែងតែទី៥ នៃសេចក្ដីសម្រេច។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ១៥ "ក" ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ របស់សាលាដំបូងខេត្តកំពង់ធំ ទុកជាបានការលើកលែងតែចំណុចទី៥ នៃសេចក្ដីសំរេចត្រង់ "អោយដើមចោទគ្រប់គ្រងលើដី និងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់កាវ៉ាអូខេ ដែលសង់លើដីទំហំ២១ម៉ែត្រគុណនឹង៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ដើម្បីទុកឲ្យកូនទាំងពីរនៅពេលមានវ័យនីតិភាព" ត្រូវកែប្រែជា "ដី និងផ្ទះសំណាក់យីហោឈានឡើង និងបន្ទប់កាវ៉ាអូខេ ដែលសង់លើដីទំហំ២១ម៉ែត្រគុណនឹង៦០ម៉ែត្រ ស្ថិតនៅភូមិថ្នល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ ត្រូវបែងចែកជាពីរចំណែកស្មើគ្នារវាងដើមចោទ និងចុងចម្លើយតាមការព្រមព្រៀងរបស់គូភាគី"។

ដីមួយកន្លែងទៀតក្នុងចំណុចទី៥ និងចំណុចផ្សេងទៀតនៃសេចក្ដីសម្រេចនៅរក្សាទុកជាបានការដដែល។

៣-ប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ជាបន្ទុករបស់ឈ្មោះ [redacted] មនោរិទ្ធ។

សាលដីកានេះទាញហេតុផលដោយផ្ទាល់មាត់ និង ប្រកាសជាសាធារណៈនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។ គូភាគីមានសិទ្ធិប្ដឹងសាទុក្ខក្នុងរយៈពេល១ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

បានឃើញបណ្ដឹងសាទុក្ខលេខ១៤៨ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់លោក [redacted] ប៊ុនសេង ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ១៥ "ក្រ.IV.ត" ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល។

ខ - **<u>អំពីសេចក្ដីថ្លែងការណ៍របស់គូភាគី</u>**

-បានស្ដាប់សេចក្ដីថ្លែងការណ៍របស់លោក [redacted] មនោរិទ្ធ នាពេលសវនាការថា: ខ្លួនប្ដឹងសាទុក្ខសុំអោយតុលាការកំពូលពិចារណាជាថ្មី បែងចែកទ្រព្យរួម និងបំណុលរួមចំនួន៧៧.៥០០ ដុល្លាអាមេរិក ជាពីរចំណែកស្មើគ្នា។

-បានស្ដាប់សេចក្ដីថ្លែងការណ៍របស់អ្នកស្រី [redacted] សេរីកញ្ញា នាពេលសវនាការថា: ខ្លួនឯកភាពលើការបែងចែកទ្រព្យរួមជាពីរស្មើគ្នា លើកលែងតែដី និងផ្ទះថ្មក្រោម ឈើលើ មានទំហំ ៧មx២៤ម មានទីតាំងស្ថិតនៅភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ គឺជាទ្រព្យដោយឡែក ដែលយាយរបស់ខ្លួនបានប្រគល់អោយខ្លួននៅមុនពេលរៀបអាពាហ៍ពិពាហ៍

៣៦៧

មកម្ល៉េះ ពុំមែនជាទ្រព្យរួមនោះទេ។ ហើយចំពោះបំណុលរួមខ្លួនទទួលស្គាល់ត្រឹមតែ១៣.៥០០ដុល្លាអាមេរិកតែប៉ុណ្ណោះ។

-បានស្តាប់សេចក្តីថ្លែការណ៍របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទនាពេលសវនាការថា: កូនក្តីខ្លួនប្តឹងមកសាលាដំបូងខេត្តកំពង់ធំ ចេញសាលក្រមសម្រេច ១-សុំលែងលះពីប្រពន្ធ, ២-សុំសិទ្ធិគ្រប់គ្រងកូនទាំងពីរនាក់, ៣-បែកចែកទ្រព្យសម្បត្តិរួម និង បំណុលរួមចំនួន៧៧.៥០០ដុល្លាអាមេរិក ជាពីរចំណែកស្មើគ្នា។ ប៉ុន្តែការសំរេចរបស់សាលាដំបូងខេត្តកំពង់ធំ និងសាលាឧទ្ធរណ៍ ពិតជាមានភាពខ្វះខាត និងធ្វេសប្រហែសយ៉ាងធ្ងន់ធ្ងរ ដោយពុំបានពិចារណាបែងចែកទ្រព្យ និងបំណុលរួមនៅឡើយទេ ជាពិសេសមិនបានបង្គាប់ឱ្យភាគីចុងចម្លើយបង់ថ្លៃអាហារកិច្ចចំពោះកូនទាំងពីរ ដែលនេះផ្ទុយនឹងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រង់មាត្រា៧០ និងមាត្រា៧៤។

-បានស្តាប់សេចក្តីថ្លែការណ៍របស់លោក [redacted] មេធាវីតំណាងដោយអាណត្តិអោយចុងចម្លើយនាពេលសវនាការថា:ការសំរេចរបស់សាលាដំបូងខេត្តកំពង់ធំ និងសាលាឧទ្ធរណ៍ គឺតាមការឯកភាពរបស់ដើមបណ្តឹង និងតាមការព្រមព្រៀងរបស់គូភាគី ដែលក្នុងនោះភាគីដើមបណ្តឹងបានធ្វើសេចក្តីថ្លែងការណ៍ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១២ ថា ខ្លួនមិនទាមទារឱ្យកូនក្តីខ្លួនបង់អាហារកិច្ចចំពោះកូនទាំងពីរនាក់នេះឡើយ។ ចំពោះការទាមទារអោយបែងចែកទ្រព្យរួមរបស់ភាគីដើមចោទ កូនក្តីខ្លួនបានឯកភាពទាំងអស់ លើកលែងតែដី និងផ្ទះថ្មក្រោមឈើលើ មានទំហំ ៧មx២៤ម មានទីតាំងស្ថិតនៅភូមិពោធិសែនស្នាយ សង្កាត់ស្រយ៉ូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ គឺជាទ្រព្យដោយឡែករបស់កូនក្តីខ្លួន។ រីឯបំណុលរួមកូនក្តីខ្លួនទទួលស្គាល់មានចំនួន១៣.៥០០ដុល្លាអាមេរិកប៉ុណ្ណោះ។ ចំណែកភាគីដើមចោទក៏ពុំមានភស្តុតាងណាមកបញ្ជាក់ថា បំណុលរួមមានចំនួនរហូតដល់៧៧.៥០០ដុល្លាអាមេរិកនោះទេ។

សំណូមពរ: សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និង សេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិឱ្យគូភាគី.

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

<u>**តុលាការកំពូល**</u>

-<u>យល់ឃើញថា</u> បណ្តឹងសាទុក្ខលេខ១៤៨ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ

៣៦៨

ជិន មានោរិទ្ធ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពសាលាជំរះក្តី និងមាត្រា២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ១៥ “ក្រIVត” ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះត្រឹមត្រូវហើយ ប៉ុន្តែដោយនៅដំណាក់កាលតុលាការកំពូល គូភាគីបានឯកភាពគ្នាសារជាថ្មីលើចំណុចខ្លះ និងមិនឯកភាពគ្នាលើចំណុចខ្លះ នៃការបែងចែកទ្រព្យសម្បត្តិរួម និងបំណុលរួមជាពីរចំណែក ហេតុនេះតុលាការកំពូលគប្បីបង្វិលសំណុំរឿងនេះ ទៅសាលាឧទ្ធរណ៍ដើម្បីពិនិត្យពិចារណាឡើងវិញ។

## ហេតុដូច្នេះ

## ឧនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ១៤៨ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] មានោរិទ្ធ។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ១៥ “ក្រ.IV.ត” ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ១៨២ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូល ជាបន្ទុករបស់ចុងចម្លើយ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤។

| | | |
|---|---|---|
| ឯកឧត្តម | [redacted] | ជាប្រធាន |
| លោក | | ជាចៅក្រម |
| លោក | | ជាចៅក្រម |
| លោក | | ជាចៅក្រម |
| លោកស្រី | | ជាចៅក្រម |
| លោក | | ក្រឡាបញ្ជី |

---

បានឃើញ

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៤

ប្រធាន

[redacted]

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម។

ភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]



Scanned with CamScanner